អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩**

## សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើសុំឲ្យដោះលែង

## កាំង ហ្គេកអ៊ាវ (ហៅ ឌុច)

នៅក្នុងសេចក្តីសម្រេចដែលបានចេញនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើសុំឲ្យដោះលែង កាំង ហ្កេកងអ៊ាវ ហៅ ឌុច ពីការឃុំខ្លួនបណ្តោះអាសន្ន។ លោក កាំង ហ្កេក អ៊ាវ សព្វថ្ងៃស្ថិតនៅក្រោមការជំនុំជម្រះលើបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភបំពានលើមាត្រាមួយចំនួននៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦។ ផ្នែកសំខាន់នៃសវនាការរបស់គាត់បានចាប់ផ្តើមនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ហើយមេធាវីការពារក្តីរបស់គាត់បានដាក់សំណើផ្ទាល់មាត់ សុំឲ្យដោះលែងរូបគាត់ដោយមានលក្ខខណ្ឌ នៅក្នុងសវនាការកាលពីថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩។

ជនជាប់ចោទត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ចាប់តាំងពីថ្ងៃ៣១ ខែកក្កដា ឆ្នាំ២០០៧។ មុនពេលត្រូវបានបញ្ជូនខ្លួនមកកាន់មន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ជនជាប់ចោទត្រូវបានឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំងរបស់តុលាការយោធាកម្ពុជាចាប់តាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩។

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការឃុំខ្លួនជនជាប់ចោទដោយតុលាការយោធាគឺផ្ទុយនឹងច្បាប់ ហើយគាត់មានសិទ្ធិស្វែងរកឧបាស្រ័យចំពោះការរំលោភសិទ្ធិរបស់គាត់ ទាំងនៅក្រោមច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថែមទៀតថា ការរំលោភសិទ្ធិរបស់ជនជាប់ចោទដោយតុលាការយោធា មិនអាចធ្លាក់បន្ទុកមកលើ អ.វ.ត.ក នោះទេ ហើយកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ក៏មិនមែនជាការបន្តពីដំណើរការនីតិវិធីនៅចំពោះមុខតុលាការយោធានោះដែរ។

អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការឃុំខ្លួនបណ្ដោះអាសន្ន គឺចាំបាច់ដើម្បីធានាឲ្យមានវត្តមានរបស់ជនជាប់ចោទ នៅក្នុងអំឡុងកិច្ចដំណើរការនីតិវិធី និងដើម្បីការការពារដល់សន្តិសុខរបស់គាត់ ព្រមទាំងការរក្សាសណ្ដាប់ធ្នាប់សាធារណៈ។ ដោយយោងលើមូលហេតុទាំងនេះ អង្គជំនុំជម្រះសាលាដំបូងបង្គាប់ថា ជនជាប់ចោទត្រូវតែស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន សម្រាប់អំឡុងពេលនៃការជំនុំជម្រះលើរូបគាត់។

ក្នុងករណីមានការផ្ដន្ទាទោសនៅចំពោះមុខ អ.វ.ត.ក ជនជាប់ចោទនឹងត្រូវបានទូទាត់សងពេលវេលាដែលបានចំណាយនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្ននៅចំពោះមុខ អ.វ.ត.ក និងនៅចំពោះមុខតុលាការយោធា។

សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង អាចរកមើលបាននៅលើគេហទំព័រ៖
http://www.eccc.gov.kh/english/cabinet/courtDoc/353/E39_5_EN.pdf

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក Lars Olsen
មន្ត្រីផ្នែកទំនាក់ទំនងច្បាប់នៃ អ.វ.ត.ក
ទូរសព្ទដៃលេខ +៨៥៥ (0) ១២ ៤៨៨ 0២៣
ទូរសព្ទលើតុ +៨៥៥ (0) ២៣ ២១៩ ៨១៤ ext. ៦១៦៩
អ៊ីមែល: olsenl@un.org

លោក រាជ សម្បត្តិ
ប្រធានផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក
ទូរសព្ទដៃលេខ +៨៥៥-១២ ៤៨៨ ១៥៦
ទូរសារ: +៨៥៥-២៣ ២១៩ ៨៤១
អ៊ីមែល: reach.sambath@eccc.gov.kh